Australian Government
Department of Education

# របាយការណ៍អនុវត្តសំរាប់ការណែនាំនៃការពិនិត្យឡើងវិញ2020នូវស្តង់ដារពិការភាពសំរាប់ការអប់រំ 2005

នៅឆ្នាំ 2020 រដ្ឋាភិបាលអូស្ត្រាលីបានពិនិត្យឡើងវិញដល់*ស្តង់ដារពិការភាពសំរាប់ការអប់រំ 2005* (ស្តង់ដារ)។ ស្តង់ដារបញ្ជាក់បំភ្លឺនូវទំនួលខុសត្រូវដែលអ្នកផ្តល់ការអប់រំមានក្រោម*ច្បាប់រើសអើងដោយសារពិការភាព 1992* (DDA)។ ស្តង់ដារជួយធ្វើយ៉ាងណាអោយសិស្សដែលមានពិការភាពអាចទទួល និងចូលរួមក្នុងការអប់រំនិងការហ្វឹកហ្វឺនដូចសិស្សដែលគ្មានពិការភាពដែរ។

របាយការណ៍នេះបង្ហាញអោយឃើញនូវអ្វីដែលរដ្ឋាភិបាលអូស្ត្រាលីបានធ្វើដើម្បីពង្រឹងការអប់រំដែលរាប់បញ្ចូលសំរាប់កុមារនិងសិស្សដែលមានពិការភាព។ ការផ្លាស់ប្តូរទាំងនេះជួយគាំទ្រ *វិធីសាស្ត្រពិការភាពអូស្ត្រាលី 2021–2031*។

## ការពង្រឹងនិងគាំទ្រសិស្សដែលមានពិការភាព និងក្រុមគ្រួសាររបស់គេ

សិស្សដែលមានពិការភាព និងក្រុមគ្រួសាររបស់គេ និងអ្នកថែរក្សា បានជំរាបយើងថា មានអំណាចមិនស្មើគ្នារវាងពួកគេនឹងបណ្តាអ្នកផ្តល់ការអប់រំ។ គេមានអារម្មណ៍ថា ត្រូវធ្វើម្ចាស់ការខ្លួនឯងដើម្បីយល់ច្បាប់និងប្រព័ន្ធអប់រំ ដើម្បីគាំទ្រអោយមានការកែសំរួលសមហេតុផល។

| ផ្លាស់ប្តូរអ្វីខ្លះ | អ្វីដែលយើងបានធ្វើមកហើយ | អ្វីដែលយើងនឹងធ្វើបន្ទាប់មក |
|---|---|---|
| **មានបោះពុម្ពព័ត៌មានបន្ថែមសំរាប់សិស្សដែលមានពិការភាពនិងក្រុមគ្រួសាររបស់គេ** | នៅខែកញ្ញា 2022<br>យើងបានបោះពុម្ពធនធានថ្មីដើម្បីជួយសិស្សដែលមានពិការភាពនិងក្រុមគ្រួសាររបស់គេ<br>អោយយល់សិទ្ធិរបស់ខ្លួនក្រោមស្តង់ដារ។<br>ធនធានទាំងនោះមានបែប Easy Read បែប Auslan<br>និងក្នុងភាសា សហគមន៍ នៅ<br>https://raisingchildren.net.au/disability/disability-rights-the-law/rights.<br><br>ធនធានទាំងនោះត្រូវបានធ្វើសហការគ្នាឆ្នៃរៀបរៀងដោយយុវជនដែលមានពិការភាព ដោយមានជំនួយពី<br>**កុមារនិងយុវជនដែលមានពិការភាពអូស្ត្រាលី**<br>(www.cyda.org.au).<br><br>យើងចែករំលែកធនធានជាមួយរដ្ឋនិងអនុរដ្ឋ<br>អ្នកផ្តល់ការអប់រំក្រៅពីរដ្ឋ និងអង្គការពិការភាពនានា<br>ដើម្បីបញ្ជូនទៅសិស្សនិងក្រុមគ្រួសារទាំងឡាយ។ | យើងនឹងបោះពុម្ពធនធានថែមទៀតអំពីស្តង់ដារដែលនឹងជួយសិស្សដែលមានពិការភាព<br>និងក្រុមគ្រួសាររបស់គេ ដើម្បីគាំទ្ររកសិទ្ធិអោយគេ។<br>ធនធានថ្មីនឹងមាន:<br>• ជំហានជំរាបអោយគេដឹងពីបារម្ភនិងដោះស្រាយការត្អូញត្អែរជាមួយសាលារបស់អ្នក<br>• វិធីគាំទ្រ<br>• ចាប់ផ្តើម: ពិការភាពនិងការអប់រំ<br>• ទស្សនៈរបស់ជនជាតិដំបូង និងជនដែលមានវប្បធម៌និងភាសាផ្សេងៗ។ |
| **ដាក់ច្បាប់អោយច្បាស់ជាងមុនលើការពិគ្រោះជាមួយសិស្សដែលមាន ពិការភាព និងក្រុម គ្រួសាររបស់គេ និងការដោះស្រាយបញ្ហានិងការត្អូញត្អែរ** | យើងធ្វើការជាមួយរដ្ឋាភិបាលនៃរដ្ឋនិងអនុរដ្ឋដើម្បីសរសេរគោលការថ្មីសំរាប់អ្នកផ្តល់ការអប់រំ<br>អោយគេដើរតាមនៅពេលពិគ្រោះគ្នាជាមួយសិស្ស<br>និងក្រុមគ្រួសាររបស់គេ<br>និងពេលដោះស្រាយបញ្ហានិងការត្អូញត្អែរ។<br><br>គោលការទាំងនេះនឹងមានដាក់នៅក្នុងស្តង់ដារ។ | យើងនឹងសូមយោបល់ពីអ្នកអប់រំ អ្នកផ្តល់ការអប់រំ<br>និងសហគមន៍ពីគោលការថ្មី<br>និងជំរើសសំរាប់ធ្វើការផ្លាស់ប្តូរដល់ស្តង់ដារ។<br><br>ការនេះនឹងជួយអោយយើងសំរេចចិត្តលើរបៀបផ្លាស់ប្តូរស្តង់ដារ។ |
| **ចែករំលែកព័ត៌មានពេលសិស្សដូរសាលា** | យើងរកវិធីចែករំលែកព័ត៌មានពេលសិស្សរើពីសាលាមួយទៅសាលាមួយ<br>ឬចាប់ផ្តើមសាលាអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ (VET)។ | យើងកំពុងបង្កើតលេខសំគាល់សិស្សឯកជនប្រចាំសាលា<br>ដែលនឹងជួយដល់ការចែករំលែកព័ត៌មានសំរាប់ទាំងអស់ដែលដូរសាលា។<br>យើងនឹងធ្វើការនេះតាមច្បាប់ស្តីពីសុខុមាលភាពនឹងកំណត់ត្រានៃការអប់រំរបស់សិស្ស។ |

## ការពង្រឹងចំណេះនិងសមត្ថភាពរបស់អ្នកអប់រំនិងអ្នកផ្តល់

បណ្តាជនបានជំរាបយើងថា អ្នកអប់រំជាច្រើនមិនដឹងពីទំនួលខុសត្រូវរបស់ខ្លួនក្រោមស្តង់ដារទេ ពុំនោះសោត គេមិនមានព័ត៌មានដែលគេត្រូវការអនុវត្តទៀតផង។ សិស្សដែលមានពិការភាពបានទទួលបទពិសោធន៍ប្រសើរជាង នៅពេលអ្នកអប់រំនិងអ្នកផ្តល់ការអប់រំរបស់គេមានការយល់ស្តង់ដារច្បាស់ ហើយដឹងពីរបៀបធ្វើតាមស្តង់ដារ។

| ផ្លាស់ប្តូរអ្វីខ្លះ | អ្វីដែលយើងបានធ្វើមកហើយ | អ្វីដែលយើងនឹងធ្វើបន្ទាប់មក |
|---|---|---|
| **បោះពុម្ពព័ត៌មានសំរាប់អ្នកផ្តល់ការអប់រំ** | នៅឆ្នាំ 2022<br>យើងបានអាប់ដេតសន្លឹកការពិតពីច្បាប់ពិការភាព និងពីរបៀបដាក់ពាក្យត្អូញត្អែរ។ ការទាំងនេះមាននៅ www.education.gov.au/disability-standards-education-2005/information<br><br>នៅឆ្នាំ 2023<br>យើងបានបោះពុម្ពព័ត៌មានធនធានថ្មីសំរាប់គ្រូនិងអ្នកដឹកនាំសាលា។<br>ព័ត៌មានទាំងនេះជួយអោយអ្នកអប់រំយល់ច្បាស់ជាងមុនពីទំនួលខុសត្រូវរបស់គេក្រោមស្តង់ដារនិងពីរបៀបអនុលោមតាមស្តង់ដារ។ ព័ត៌មានទាំងនេះមាននៅឯ www.aitsl.edu.au/teach/supporting-students-with-disability និង www.nccd.edu.au/dse. | |
| **ផ្តល់ការហ្វឹកហ្វឺនលើស្តង់ដារសំរាប់គ្រូនិងអ្នកដឹកនាំសាលា** | អតីតមន្ត្រីអប់រំបានសរសេរទៅអាជ្ញាធរអប់រំសាលាទាំងឡាយ<br>សូមអោយគេធ្វើយ៉ាងណាអោយគ្រូនិងអ្នកដឹកសាលាទទួលការហ្វឹកហ្វឺនជំនាញលើស្តង់ដារ។ | អាជ្ញាធរអប់រំសាលានឹងដឹកនាំការងារនេះ<br>ព្រោះគេមានទំនួលខុសត្រូវលើការជួលគ្រូ។ |
| **ផ្តល់ធនធានសំរាប់អ្នកផ្តល់ VET** | យើងកំពុងបង្កើតធនធានដើម្បីណែនាំអ្នកផ្តល់ VET អោយដឹងពីរបៀបគាំទ្រពេញគ្រាហ្វឹកហ្វឺនដល់សិស្សដែលមានពិការភាព។ | យើងនឹងធ្វើការជាមួយរដ្ឋនិងអនុរដ្ឋទាំងឡាយ និងអ្នកគ្រប់គ្រង VET<br>អោយប្រមូលនិងចែកចាយធនធានទាំងនេះ។ |
| **រាប់បញ្ចូលស្តង់ដារក្នុងសំណុំក្រឹតក្រមនិងការអនុវត្តទាំងឡាយនៃការអប់រំជាន់ខ្ពស់** | យើងបានសួរ**មណ្ឌលជាតិសំរាប់សិស្សស្មើភាពក្នុងការអប់រំជាន់ខ្ពស់**<br>សូមយោបល់លើវិធីបញ្ចូលស្តង់ដារក្នុងសំណុំក្រឹត្យក្រមនិងការអនុវត្តទាំងឡាយនៃការអប់រំជាន់ខ្ពស់។<br><br>ផ្នែកមួយនៃថវិកាប្រចាំឆ្នាំ 2023–24 គឺប្រាក់គឺបន្ថែម $4.3 លាននឹងត្រូវធ្វើវិនិយោគរាល់ឆ្នាំក្នុងប្រូក្រាមគាំទ្រពិការភាពអប់រំជាន់ខ្ពស់<br>ដើម្បីជួយសាកលវិទ្យាល័យគាំទ្រសិស្សដែលមានពិការភាពអោយបានប្រសើរជាងមុន។<br>ព័ត៌មានបន្ថែមមាននៅក្នុងសន្លឹកការពិតនៃថវិកាប្រចាំ 2023–24 www.education.gov.au/about-department/resources/budget-2324-factsheet-higher-education-support-students-disability. | យើងនឹងធ្វើការជាមួយអង្គការអប់រំជាន់ខ្ពស់លើរបៀបដែល**កម្មវិធីគាំទ្រពិការភាពអប់រំជាន់ខ្ពស់**អាចជួយសកលវិទ្យាល័យអោយគាំទ្រដល់សិស្សដែលមានពិការភាព។<br><br>រដ្ឋាភិបាលអូស្ត្រាលីបានសួរអ្នកឯកទេសមួយក្រុម គឺក្រុមអនុម័តសកលវិទ្យាល័យអូស្ត្រាលី<br>អោយរកវិធីកែលំអដល់ប្រព័ន្ធអប់រំជាន់ខ្ពស់នៃប្រទេសអូស្ត្រាលី។<br>នេះមានរាប់បញ្ចូលទាំងការរកវិធីធ្វើអោយបណ្តាសិស្សដែលមិនសូវមានគេតំណាងអោយមកទទួលការអប់រំជាន់ខ្ពស់។ |

## ទំនួលខុសត្រូវបន្ថែមសំរាប់ស្តង់ដារទូទាំងប្រព័ន្ធអប់រំ

បណ្តាជនបាននិយាយថាត្រូវមានការកែលំអដល់ទំនួលខុសត្រូវក្នុងការធ្វើយ៉ាងណាអោយមានការអនុលោមតាមស្តង់ដារ។ គេចង់បានព័ត៌មានបន្ថែមអំពីរបៀបដែលអ្នកផ្តល់ការអប់រំអនុលោមតាមស្តង់ដារ។

| ផ្លាស់ប្តូរអ្វីខ្លះ | អ្វីដែលយើងបានធ្វើមកហើយ | អ្វីដែលយើងនឹងធ្វើបន្ទាប់មក |
|---|---|---|
| **ធ្វើយ៉ាងណាអោយសំណុំក្រឹត្យក្រមអប់រំត្រូវគ្នានឹង ស្តង់ដារ** | យើងធ្វើការជាមួយរដ្ឋាភិបាលនៃរដ្ឋនិងអនុរដ្ឋដើម្បីធ្វើយ៉ាងណាអោយច្បាប់និងសំណុំក្រឹត្យក្រមអប់រំត្រូវគ្នានឹងស្តង់ដារ។<br><br>ការពិនិត្យឡើងវិញនូវកម្មវិធីសិក្សាអូស្ត្រាលីរវាងឆ្នាំ 2020 និង 2022 មានរាប់បញ្ចូលទាំងការធ្វើយ៉ាងណាអោយកម្មវិធីសិក្សាបានបើកចំហដល់សិស្សទាំងអស់ ហើយអនុលោមតាមស្តង់ដារទៀត។<br><br>យើងឆែកមើលថាតើក្របខ័ណ្ឌជាតិសំរាប់គ្រូនិងចាងហ្វាងត្រូវគ្នានឹងស្តង់ដារឬអត់។<br><br>យើងបោះពុម្ពវិឌីអូថ្មីៗបង្ហាញពីរបៀបគ្រូនិងអ្នកដឹកនាំសាលាអាចអនុលោមតាមស្តង់ដារ ហើយគាំទ្រសិស្សដែលមានពិការភាព។ ព័ត៌មានទាំងនេះមាននៅឯ www.aitsl.edu.au/teach/supporting-students-with-disability និង www.nccd.edu.au/dse. | កម្មវិធីសិក្សាដែលបានអាប់ដេតរួចហើយ(v9.0) កំពុងត្រូវបានយកមកប្រើក្នុងសាលាទាំងឡាយចាប់ពីឆ្នាំ 2023។ |
| **កែលំអ VET សំរាប់សិស្សដែលមានពិការភាព** | *ស្តង់ដារសំរាប់អង្គការហ្វឹកហ្វឺនដែលបានចុះឈ្មោះហើយ 2015* (ស្តង់ដារ RTO) កំពុងត្រូវកែឡើងវិញ។ កំណែទាំងប៉ុន្មានមានរាប់បញ្ចូលតំរូវការខ្លាំងជាងមុនសំរាប់ជំនួយសិស្សនិងសុខុមាលភាព ដើម្បីធ្វើយ៉ាងណាអោយការកែសំរួលសមហេតុផលត្រូវធ្វើឡើងសំរាប់សិស្សដែលមានពិការភាព។ | ស្តង់ដារ RTO ព្រាងដែលបានកែឡើងវិញកំពុងតែត្រូវសាកល្បង។ យើងនឹងបន្តធ្វើការជាមួយរដ្ឋនិងអនុរដ្ឋទាំងឡាយ ដើម្បីកែសំរួលស្តង់ដារព្រាងថែមទៀត មុននឹងសូមការអនុម័តពីបណ្តាមន្ត្រីជំនាញ ដើម្បីអនុវត្តស្តង់ដារដែលបានកែឡើងវិញចាប់ពីខែមករា2025។ |
| **បោះពុម្ពព័ត៌មានបន្ថែមអំពីរបៀបសាលាគាំទ្រសិស្សដែលមានពិការភាព** | យើងកំពុងធ្វើការជាមួយរដ្ឋនិងអនុរដ្ឋទាំងឡាយ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីកែលំអដល់ការផ្តល់ព័ត៌មានអំពីសេវាកម្មនិងជំនួយគាំទ្រដែលសាលាផ្តល់ដល់សិស្សដែលមានពិការភាព។ | យើងនឹងបន្តធ្វើការជាមួយរដ្ឋនិងអនុរដ្ឋទាំងឡាយ និងអង្គការមិនមែនរដ្ឋាភិបាល លើវិធីប្រមូលនិងចែករំលែកព័ត៌មានជាសាធារណ:អំពីរបៀបសាលាទាំងឡាយជួយគាំទ្រសិស្សដែលមានពិការភាព។ |
| **ឆែកមើលថាតើស្តង់ដារត្រូវបានអនុលោមបានល្អប៉ុនណា** | អតីតមន្ត្រីអប់រំបានសរសេរទៅសវនករទូទៅនៃរដ្ឋនិងអនុរដ្ឋ អំពាវនាវអោយគេធ្វើសវនកម្មដើម្បីឆែកមើលថាតើស្តង់ដារត្រូវបានប្រព្រឹត្តតាមបានល្អប៉ុនណាក្នុងសាលារបស់រដ្ឋ។<br>អតីតមន្ត្រីក៏បានសរសេរទៅមន្ត្រីខំមិនរ៉េលឯទៀតដែរ រំលឹកគេថាសំណុំមុខងាររបស់គេគឺត្រូវធ្វើតាមស្តង់ដារក្នុងកម្មវិធីអប់រំដែលគេបង្កើតមក។ | ផ្នែកមួយនៃការពិនិត្យស្តង់ដារឡើងវិញ2025 គឺយើងនឹងសួរសវនករទូទៅនៃរដ្ឋនិងអនុរដ្ឋ អោយជំរាបយើងនូវអ្វីដែលគេបានរៀនដឹងក្នុងការធ្វើសវនកម្មរបស់គេ។ |

## បង្កើនភាពដឹងខ្លួននិងសមត្ថភាពក្នុងការអប់រំកុមារវ័យដំបូងនិងអង្គការថែទាំ

បច្ចុប្បន្ននេះស្តង់ដារមិនបានប្រើសំរាប់អ្នកផ្តល់ការថែទាំកុមារទេ ប៉ុន្តែអ្នកផ្តល់ការថែទាំត្រូវគោរពច្បាប់មិនរើសអើងដែលបានចែងនៅក្នុង DDA។ មានការ គាំទ្រយ៉ាងខ្លាំងក្នុងការធ្វើយ៉ាងណាអោយអ្នកអប់រំនិងអ្នកផ្តល់ការថែទាំនិងអប់រំកុមារភាពវ័យដំបូង(ECEC) បានយល់ជាងមុននូវទំនួលខុសត្រូវនិង កាតព្វកិច្ចរបស់គេក្រោម DDA រួមទាំងធ្វើការកែសំរួលសមហេតុផលសំរាប់កុមារដែលមានពិការភាពដែលទទួលសេវាកម្មរបស់គេ។

| ផ្លាស់ប្តូរអ្វីខ្លះ | អ្វីដែលយើងបានធ្វើមកហើយ | អ្វីដែលយើងនឹងធ្វើបន្ទាប់មក |
|---|---|---|
| **បោះពុម្ពព័ត៍មានសំរាប់អ្នក ផ្តល់ ECEC** | នៅឆ្នាំ 2022 និង 2023 **ការអប់រំនៃកុមារអូស្ត្រាលីនិងអាជ្ញាធរគុណភាពថែទាំ** (ACECQA) បានបោះពុម្ពធនធានថ្មីដើម្បីជួយអ្នកផ្តល់ECEC អោយស្វែងរកនិងយល់ដឹងអំពី DDA។ ធនធានទាំងនេះមាននៅឯ www.acecqa.gov.au/resources/disability-discrimination-act-1992-dda-resources. | ACECQA កំពុងជួយសេវាកម្ម ECEC ទាំងឡាយអោយស្វែងរកនិងប្រើធនធានទាំងអំបាលមាណ។ |
| **ធ្វើយ៉ាងណាអោយ ECEC ត្រូវនឹងសំណុំក្រឹត្យក្រម របស់ DDA** | ក្នុងការអាប់ដេតនៅឆ្នាំ 2022 ព័ត៍មានបន្ថែមអំពីរបៀបគាំទ្រក្មេងមានពិការភាពក្នុង ECEC ត្រូវបានបញ្ចូលរួចហើយទៅក្នុងក្របខ័ណ្ឌសិក្សាប្រចាំជាតិដែលត្រូវបានអនុម័ត។ ព័ត៍មានទាំងនោះគឺ:<br>• **ជាប់ខ្សែរយៈ រស់រាន ក្លាយជា: ក្របខ័ណ្ឌរៀនសូត្រនៅវ័យដំបូងសំរាប់ប្រទេសអូស្ត្រាលី**<br>• **វេលាខ្ញុំ កន្លែងយើង: ក្របខ័ណ្ឌសំរាប់ថែរក្សាក្មេងមានអាយុចូលសាលាក្នុងប្រទេសអូស្ត្រាលី** | យើងនឹងធ្វើការជាមួយ ACECQA ដើម្បីបញ្ចូលព័ត៍មានពិស្តារថែមទៀតអំពីរបៀបគាំទ្រកុមារដែលមានពិការភាពក្នុង ECEC ក្នុង**ការណែនាំអំពីក្របខ័ណ្ឌគុណភាពជាតិ**។ |
| **ដូរស្តង់ដារអោយបញ្ចូល ECEC ផងដែរ** | យើងបានធ្វើការជាមួយរដ្ឋាភិបាលនៃរដ្ឋនិងអនុរដ្ឋ អង្គការអប់រំដែលមិនមែនរដ្ឋាភិបាល ACECQA និង អំពីរបៀបផ្លាស់ប្តូរស្តង់ដារដើម្បីបញ្ចូល ECEC។ | យើងនឹងពិគ្រោះជាមួយអង្គការ ECEC និងសហគមន៍ពិការភាពអំពីកំណែព្រាងដល់ស្តង់ដារ។ |

**ធ្វើការផ្លាស់ប្តូរ**

ការផ្លាស់ប្តូរខ្លះៗដែលបានរាយចុះនៅទីនេះគឺជាអ្វីដែលរដ្ឋាភិបាលអូស្ត្រាលីអាចធ្វើដោយខ្លួនឯងបាន ប៉ុន្តែភាគច្រើនត្រូវការការយល់ស្របពីរដ្ឋាភិបាលនៃរដ្ឋនិងអនុរដ្ឋ ដើម្បីធ្វើការផ្លាស់ប្តូរ ហើយនឹងធ្វើការជាមួយគ្នានឹងរដ្ឋាភិបាលអូស្ត្រាលី។ ខ្លះទៀតត្រូវការពីរដ្ឋាភិបាលនៃរដ្ឋនិងអនុរដ្ឋ និងអាជ្ញាធរអប់រំ ដែលចាត់ចែងសាលាដើម្បីធ្វើការផ្លាស់ប្តូរ ឬធ្វើអ្វីថ្មី។

ការផ្លាស់ប្តូរកំពុងតែត្រូវបានធ្វើឡើងដោយមានជំនួយនិងឱវាទពីអ្នកតំណាងការអប់រំ និងពីបណ្តាជនដែលមានពិការភាព។

សំរាប់ព័ត៍មានបន្ថែម សូមទៅ www.education.gov.au/disability-standards-education-2005.